កិច្ចសម្ភាសរបស់ ពុម ស្តើង

ក អ្នកសម្ភាស ថន រដ្ឋា **ខ អ្នកត្រូវបានសម្ភាស ពុម ស្តើង**

ក ៖ បាទ នៅថ្ងៃនេះគឺថ្ងៃទីពីរ ខែធ្នូ ឆ្នាំពីរពាន់ប្រាំបួន។ ហើយខ្ញុំបាទឈ្មោះ ថន រដ្ឋា គឺជាក្រុមការងារគម្រោងប្រវត្តផ្ទាល់ខ្លួនរបស់ប្រជាជនកម្ពុជា គម្រោងនេះត្រូវបានខបត្ថម្ភដោយសាកលវិទ្យាល័យ BYU នូវសហរដ្ឋអាមេរិចដែលមាន Website: http:cambodianoralhistories.byu.edu.ហើយថ្ងៃនេះខ្ញុំបាទមកជួបនូវអ៊ំស្រី ពុម ស្តើងបច្ចុប្បន្នអ៊ំស្រីមានអាយុប៉ែតសិបបីឆ្នាំ ហើយអ៊ំស្រីរស់នូវភូមិគោកដូង ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង។

អញ្ចឹងគោលបំណងនៃការសម្ភាសនេះគឺដើម្បីរក្សាទុកនូវកំណត់ត្រាដូចជាពង្សប្រវត្តរបស់លោកយាយផ្ទាល់សម្រាប់ទុកអោយកូនចៅជំនាន់ក្រោយ មួយទៀតដើម្បីអោយពួកខ្ញុំបានរៀនសូត្រអំពីបទពិសោធន៍ ហើយនឹងមតិយោលបល់របស់លោកយាយផងដែរ អញ្ចឹងជាបន្តខ្ញុំនឹងជម្រាបសួរទៅកាន់លោកយាយ ហើយលោកយាយសុំជួយជម្រាបឈ្មោះម្តងទៀតផង លោកយាយឈ្មោះអីម្តងទៀត?

ខ ៖ ពុម ស្តើង។

ក ៖ លោកយាយមានឈ្មោះហៅក្រៅទេ?

ខ ៖ ឈ្មោះហៅក្រៅ ម៉ែអាផាត់ ដាក់ឈ្មោះកូន។

ក ៖ ហៅម៉ែអីគេ?

ខ ៖ ហៅម៉ែផាត់។

ក ៖ ហៅម៉ែអាផាត់។ ហើយកាលលោកយាយនូវពីតូចលោកយាយមានឈ្មោះហៅក្រៅទេ?

ខ ៖ អត់។

ក ៖ លោកយាយមានចេះភាសារអីក្រៅពីភាសារខ្មែរទេ?

ខ ៖ អត់ចេះផង មនុស្សចាស់ពីដើមល្ងង់មានចេះអីទេ។

ក ៖ លោកយាយអាចសរសេរបានអាចអានបានទេ ភាសារខ្មែរ?

ខ ៖ អត់។

ក ៖ ស្រុកកំណើតរបស់លោកយាយនូវឯណា?

ខ ៖ នូវភូមិថ្មីកំពង់សីមាប៉ុនសង្ក្រាមចប់ទៅខ្ញុំមកតាមនៅជាមួយប្អូននេះទៅ បានគ្រួសារនេះឯង។

ក ៖ បច្ចុប្បន្នលោកយាយអាយុប៉ុន្មានហើយ?

ខ ៖ ហាស់!

ក ៖ ឥឡូវនេះលោកយាយអាយុប៉ុន្មានហើយ?

ខ ៖ ប៉ែតបី។

ក ៖ ឆ្នាំខ្មែរគេហៅឆ្នាំអីលោកយាយ?

ខ ៖ ឆ្នាំខាល។

ក ៖ លោកយាយបានរៀបការយូរនូវ?

ខ ៖ បានពីអាយុខ្ញុំនូវស្រុកណោះ បានប្តីស្រុកណោះបានកូនមួយ ហើយមកនេះកូនមួយឈ្មោះអាផាត់នឹងឯង ទៅមកនូវណេះបានប្តីមួយទៀត បាននឹងពីអាយុសែពីរនូវស្រុកគោកដូង។

ក ៖ លោកកយាយស្គាល់គ្នាតាមណា?

ខ ៖ ចាស់?

ក ៖ លោកយាយស្គាល់គ្នាតាមណា? ប្តីរបស់លោកយាយប្តីមុនប្តីក្រោយស្គាល់គ្នាដោយរបៀបមិច? លោកយាយជួយរៀបរាប់បន្តិចថា ហេតុអ្វីបានជាលោកយាយស្គាលគ្នាជាមួយប្តីបោះលោកយាយ?

ខ ៖ ធ្វើការជាមួយគ្នាពីយើងមកពីធ្វើការរួម ទៅគេសុំយកទៅ។

ក ៖ ប្តីមុនមែន?

ខ ៖ ប្តីក្រោយនេះណា។

ក ៖ បាទ ចុះប្តីមុន?

ខ ៖ ប្តីមុនក៏សុំដែរព្រោះខ្ញុំជនជាតិអ៊ីស្លាម។

ក ៖ បាទ។

ខ ៖ ដល់ពេលអ៊ំខ្ញុំខ្មែរ ខិពុកខ្មែរគាត់ថាសុំខ្ញុំមួយទៅជាខ្មែរទៅ បានៗខ្មែរ។

ក ៖ ហើយកាលដែលស្គាល់គ្នារៀបការមួយពួកគាត់ តើលោកយាយយកថ្លៃបណ្ណការប៉ុន្មាន?

ខ ៖ អត់រៀប ពីជំនាន់នោះប្រាក់ថ្លៃណាស់អាអូនមាសមួយជីមួយពាន់ ជំនាន់នឹងណាយកថ្លៃប្រាំមួយប្រាំពីរពាន់ទៅរៀបបានហើយ
យើងសម័យនេះអោយតែស្រឡាញ់គ្នាបានដឹងតែការ មុនស្រឡាញ់គ្នាអញ្ចឹងដឹងតែគេសុំអញ្ចឹងដឹងតែអត់បានថ្លៃហើយព្រោះកូនខ្ញុំមួយស៊ីជិតប្រាំពីរពាន់ការមីស្រីមួយនូវផ្ទះធំ។

ក ៖ បាទ អញ្ចឹងលោកយាយពេញចិត្តប្តីបោះលោកយាយត្រង់លក្ខណៈត្រង់ណា?

ខ ៖ វាពេញចិត្តមិនពេញទាំងស្រឡាញ់គេសុំហើយទៅយើងទៅជាមួយគេ ហើយមេម៉ាយកូនមួយអាផាត់នូវតូច ហើយមីស្រីនោះទើបការផង.

ក ៖ បាទ ខ្ញុំនឹងជម្រាបសួរទាក់ទងទៅនឹងអ៊ំស្រីហើយនឹងឪពុកម្តាយវិញម្តង តើលោកយាយជាកូនទីប៉ុន្មានក្នុងក្រុមគ្រួសារ?

ខ ៖ កូនបង កូនទីបងប្អូនៗងាប់អស់ហើយ។

ក ៖ មានបងប្អូនប៉ុន្មាននាក់?

ខ ៖ បងប្អូនប្រាំពីរនាក់ងាប់អស់ ប្រុសនូវបីនាក់ ងាប់ស្រីអស់បួននាក់ ប្រុសទៀត។

ក ៖ ប្រាំពីរនាក់ទៀតណ៎?

ខ ៖ ចាស់។

ក ៖ ប្រុសបួនស្រីបី។

ខ ៖ ចាស់។

ក ៖ លោកយាយជួយប្រាប់ឈ្មោះពួកគាត់ទាំងអស់?

ខ ៖ ជម្រាប់ម្នាក់ ម្នាក់នឹងមីខន ហើយនូវទន្រ្ទាយម្នាក់នឹងឈ្មោះ មីស៊ីផាននូវឆ្ងាយៗ។

ក ៖ បាទនូវណាទៀត?

ខ ៖ នូវតែបី នូវសៀមរាបមួយខ្ញុំមួយ នូវទន្រ្ទាយមមួយនូវស្រុកទន្រ្ទាយ។

ក ៖ ចុះអ្នកស្លាប់ៗនឹងដោយសារអីគាត់អាយុប៉ុន្មាន?

ខ ៖ ស្លាប់ពីអាពតអស់នេះសង្រ្គាមប៉ុន្តែថាចែកប្រេងកាលនឹងនិយាយខុសចុចយកទៅអោយវ៉ៃចោល។

ក ៖ និយាយខុស។

ខ ៖ នឹងហើយ។ ហើយពុកអាផាត់ក៏អញ្ចឹងដែរមិនមែងងាប់តាមទន្រ្ទត់ទេឈឺចាប់វាខឹង ថាសុំថ្លៃ ដូចយើងដាំពោតមួយជួរយើងទៅ
ក៏ដាំស្រូវមួយជួរអញ្ចឹងទៅក្រោយដាំពោតអញ្ចឹងទៅដង្ហែលទៅដល់កាប់ធ្វើចំការក្រោយវត្តតាខ្មៅនឹងវានឿយពេក ឆ្ការចំការវាធំអោយយើងធ្វើតែម្នាក់យើងសុំគេថា
សុំស្នើរយកពីរនាក់ទៀតធ្វើអោយរួចចំការនឹងរហ័សរួច ថាយើងតថ្លៃ។

ក ៖ ទៅគេយកទៅវ៉ៃចោលទៅ។

ខ ៖ លោតពីលើផ្ទះដែលធ្វើសាលារៀនយោរធាគេមកនូវអាកន្លែងល្អៗសាលារៀនគេទៅសួរថាធ្វើអី ខ្ញុំថាឈឺណូមយើអានទៅណូមអញ្ចឹង
ក៏យោរធាប្រទេសជាតិច្រានវាចាប់ចប់យើងចាប់មិនចប់វាធ្លាក់មកក្រោមវាបាញ់សរុបពីលើទៀត នឹងកូននខ្ញុំបានប្រាំពីរឆ្នាំផាត់ៗនឹងបានប្រាំពីរឆ្នាំ។

ក ៖ វាច្រានទម្លាក់ពីលើ?

ខ ៖ វាច្រាន។

ក ៖ ហើយបាញ់ថែម?

ខ ៖ សាលាធ្វើអាប្រាំជាន់ សាលារៀនគូរក្មេងវាបាញ់។

ក ៖ វាព្រួតគ្នាធ្វើបាបអ៊ំប្រុស។

ខ ៖ មនុស្សនឹងត្រង់ហួស បើមិនត្រង់ ប៉ុនថាអាយុត្រូវងាប់គេចក៏មិនផុតដែរគេសួរចាប់ឈ្មោះផ្សេងសួរឈ្មោះយើង គេចង្អុលថាខ្ញុំណែឈ្មោះនឹងឯង។

ក ៖ អរ! ការពិតសួរអ្នកផ្សេងទេ?

ខ ៖ ចាស់។

ក ៖ គាត់រោងគ្រោះជំនួស?

ខ ៖ រោងគ្រោះ មនុស្សគាត់ត្រង់ពេក។

ក ៖ មនុស្សត្រង់។

ខ ៖ បងខ្ញុំមួយឆ្នាំ ឆ្នាំស្លូវ ខ្ញុំឆ្នាំខាល បើយោរធាផ្សេងៗអត់ទេ
ខ្ញុំបានរសនឹងយោរធាផ្សេងវាហៅអោយខ្ញុំទៅដាំបាយទៅស្លអណ្តើកគេអោយស៊ីទៅថ្នាំអីខ្ញុំហាន់អោយគេទៅគេអោយមួយទាំងគីឡូៗអង្ករកើបអោយទាំងឆ្នាំងៗយកទៅម៉ែយកទៅ
ដាំបាយអាអូនស៊ីយោរធាខ្លះវាចិត្តបាន។

ក ៖ បាទ។

ខ ៖ ខ្លះអត់ទេ ប៉ុនវាមិនសល់វាងាប់អស់ហើយពួកអានឹងធ្វើបាបគេគេធ្វើបាបវាតគ្នា

ក ៖ អញ្ចឹងម្តាយរបស់លោកយាយឈ្មោះអីដែរ?

ខ ៖ ឈ្មោះ លីហេង។

ក ៖ គាត់ស្រុកកំណើតនូវខេត្តណា?

ខ ៖ នូវភូមិថ្មី ពាមសីមានឹង។

ក ៖ ខេត្តបាត់ដំបង?

ខ ៖ ចាស់។

ក ៖ អាយុគាត់កាលនឹងប៉ុន្មាន?

ខ ៖ គាត់ឆ្នាំមមែ ឱពុកឆ្នាំស្លូវ អរ ឆ្នាំថោះ។

ក ៖ មានដឹងពីឆ្នាំដែលគាត់ ថ្ងៃខែដែលគាត់កើតទេ?

ខ ៖ គាត់ឆ្នាំមមែនឹង។

ក ៖ ថ្ងៃខែគាត់?

ខ ៖ មិនដឹងទេដឹងតែឆ្នាំមមែឱពុកឆ្នាំថោះ។

ក ៖ មានដឹងប្រវត្តម្តាយគាត់មិចដែរ? ប្រវត្តរបស់ម្តាយរបស់លោកយាយ?

ខ ៖ ចាស់។

ក ៖ គាត់ប្រកបរបររកស៊ីអីដែរ?

ខ ៖ គាត់រកស៊ី អ្នកកូដមានរកស៊ីអី រកស៊ីតែកូដដាក់មុង។

ក ៖ ហើយអ្នកម្តាយរបស់លោកយាយមានបងប្អូនប៉ុន្មាននាក់?

ខ ៖ ខ្ញុំចាំមិនអស់ទេច្រើនណាស់ មាននូវសល់ម្នាក់។

ក ៖ មានស្គាល់ម្នាក់ពីរនាក់អត់?

ខ ៖ ស្គាល់ប៉ុនងាប់អស់។

ក ៖ បាទ ហើយហេតុអ្វីបានគាត់?

ខ ៖ ខូច នឹងពីសម័យអាពតពីរបីនាក់ទៅ ហើយគាត់អាយុក៏ត្រឹមនឹងទៅ។

ក ៖ យាយតាខាងម្តាយឈ្មោះអ្វីដែរ?

ខ ៖ យាយតា អ៊ុង លីហៀងនឹងឯង។

ក ៖ ស្រុកកំណើតបោះគាត់កើតនូវណាវិញ?

ខ ៖ កើតនូវភូមិថ្មីកំពង់សីមា។

ក ៖ ចុះគាត់អាយុប៉ុន្មានហើយ?

ខ ៖ ខ្ញុំមេយើញប៉ុន្មានគិតមើលតិចទេមាជូរនឹងមាជូរចាស់ពីដើម។

ក ៖ លោកយាយមានស្គាល់ឆ្នាំដែលគាត់កើតទេ?

ខ ៖ គាត់កើតឆ្នាំថោះ ម្តាយឆ្នាំមមែឱពុកឆ្នាំថោះ។

ក ៖ ប្រវត្តបោះពួកគាត់មិចដែរ? គាត់រកស៊ីអីប្រកបមុខរបរអីប្រឹងប្រែងជីវភាព?

ខ ៖ ប្រឹងប្រែងជីវភាពទៅរកឯណាមាជំនាន់ពួកខ្ញុំនូវក្មេង ខ្ញុំនូវតាំងពីក្មេងតាំងពីអាយុដប់បួនឆ្នាំនូវដល់ចាស់ប៉ុណ្ណោះ។

ក ៖ អញ្ជឹងស្រុកកំណើតលោកឱពុករបស់លោកយាយនូវខេត្តណាដែរ?

ខ ៖ នូវភូមិថ្មីពាមសីមានឹងឯង។

ក ៖ បើគិតពេលនោះគាត់អាយុប៉ុន្មានដែរ?

ខ ៖ ឆ្នាំថោះ បើនូវដល់ឥឡូវវាចូល ចង់ចូលកៅហើយ កូនបងគេកៅសិបសិបជាងហើយអាអូន។

ក ៖ លោកយាយមានដឹងឆ្នាំដែលឱពុកបោះលោកយាយកើតទេ?

ខ ៖ ឆ្នាំថោះ។

ក ៖ ខែអី?

ខ ៖ ខែបង្គង់។

ក ៖ ថ្ងៃអី?

ខ ៖ ថ្ងៃអាទិត្យ។

ក ៖ គាត់ខូចទៅគាត់ដឹងថ្ងៃគាត់ គាត់សួរខ្ញុំថាថ្ងៃនេះថ្ងៃអីកូនខ្ញុំថាថ្ងៃអាទិត្យ ចាអញ្ជឹងឱពុកណាកូនឯងហើយចាដល់ផុតពីមាត់គាត់ខូច។

ក ៖ ឱពុករបស់លោកយាយមានបងប្អូនប៉ុន្មាននាក់?

ខ ៖ មិនដឹងមាជំនាន់ចាស់ៗនឹងងាប់ ងាប់ខ្លះនឹងអាសន្នរោគណាអូនមួយឆ្នាំមានសន្នរោគ។

ក ៖ សន្នរោគអីគេ?

ខ ៖ សន្នរោគជំងឺណា ជំងឺមកម្តុំបើអ៊ំខ្ញុំបងពុកខ្ញុំនឹងគាត់ខូចទាំងប្តីទាំងប្រពន្ធប្តីខូចព្រឹក ប្រពន្ធខូចល្ងាច។

ក ៖ កើតអី?

ខ ៖ អាសន្នរោគនឹង។

ក ៖ មកពីណារោគនឹង?

ខ ៖ រោគឈឺ ឈឺដឹងតែងាប់មែនដូចយើងមានពេទ្យ មានអីចាក់ដូចឥឡូវឯណាអាអូន។

ក ៖ ហើយអញ្ចឹងជីដូនជីតាខាងឱពុកវិញគាត់ឈ្មោះអីដែរ?

ខ ៖ ខ្ញុំមិនដឹងដែរ អត់ដឹង។

ក ៖ ធ្លាប់លឺឱពុកលោកយាយនិយាយអំពីគាត់ទេ?

ខ ៖ អត់ ក្រណាស់អាអូនអើយរកតែប្រាប់កូន បើខ្ញុំផងនូវតាំងពីអាតុដប់ប្រាំបួន

ដប់ប្រាំមួយឆ្នាំនឹងថាអញ្ចក់ទៅបានមួយទូកនឹងដឹកមកបាត់ដំបងទៅលក់ទៅយកទៅទិញអង្ករជីវិញ។

ក ៖ លោកយាយមានបងប្អូនដែលនូវក្រៅប្រទេសទេលោកយាយ?

ខ ៖ អត់។

ក ៖ លោកយាយផ្ទាល់មានកូនប៉ុន្មាននាក់?

ខ ៖ កូនតែពីរទេ។

ក ៖ ប្រុសប៉ុន្មាន? ស្រីប៉ុន្មាន?

ខ ៖ ប្រុសមួយស្រីមួយ។

ក ៖ គាត់ឈ្មោះអ្វីខ្លះ?

ខ ៖ ឈ្មោះសូនមួយ ឈ្មោះផាត់មួយ។

ក ៖ ស្រុកកំណើតគាត់នូវណា?

ខ ៖ នូវនេះឯង។

ក ៖ មុខរបរបោះគាត់ធ្វើអីដែរលោកយាយ?

ខ ៖ ធ្វើស្រែ។

ក ៖ តើគាត់ដៀបការហើយនូវ?

ខ ៖ ការហើយកូនមួយពីរមានទាំងចៅទៅទៀត។

ក ៖ ហើយលោកយាយមានចៅប៉ុន្មានដែរ?

ខ ៖ ចៅមានប្រាំបួននាក់។

ក ៖ លោកយាយជួយដៀបរាប់ឈ្មោះចៅលោកយាយបានទេ?

ខ ៖ ចៅ យាគៀក យាកាន កននឹងចៅ។

ក ៖ បាទ បានបីនាក់នូវប៉ុន្មានទៀត?

ខ ៖ អស់ទួតប៉ុន្នឹងឯងចៅទួត។

ក ៖ បាទ ចៅទួតនឹងឯង?

ខ ៖ ចៅទួតនឹងច្រើន។

ក ៖ លោកយាយជួយរាប់បន្តិចមក?

ខ ៖ ចៅទួតម្នាក់កូនបី ឯណោះបីប្រាំមួយ មីយាគៀកកូនពីរបីប្រាំបីនាក់។

ក ៖ អញ្ចឹងចៅទាំងអស់សរុបប្រាំបីនាក់លោកយាយ?

ខ ៖ ចាស់។

ក ៖ ពួកគាត់នូវដៀនឬក៏មិចដែរ?

ខ ៖ ដៀន។

ក ៖ ពួកគាត់ដៀននូវសាលាណាលោកយាយ?

ខ ៖ សាលាសមន្សនឹងទីប្រាំពីរ ហើយនូវឯណោះទីប្រាំមួយទីប្រាំ ទីបួនទីបីនឹងឯងតាមចាំ។

ក ៖ អញ្ចឹងកាលពីតូចអាំស្រី ឥឡូវសុំសូរអាំប្រុសមុនអាំប្រុសដៀននូវទីណាដែរ?

ខ ៖ អរ ខ្ញុំពីតូចខ្ញុំដៀននូវសាលាវត្តឯកភ្នំ។